| | |
|---|---|
| គោលដៅប្រតិបត្តិការ | ·រួមចំណែកក្នុងការពង្រឹងស្ថេរភាពគ្រួសារ និងធ្វើឱ្យទំនាក់ទំនងគ្រួសារកាន់តែប្រសើរឡើង ដោយផ្តល់នូវសេវាកម្មជាសកល និងទូលំទូលាយសម្រាប់គ្រួសារទាំងឡាយនៅខណ្ឌស៊ូសុង។<br>·លើកកម្ពស់ការតាំងទីលំនៅដំបូងនៅក្នុងសង្គមកូរ៉េ និងការគាំទ្រពឹងផ្អែកលើខ្លួនឯងនៅក្នុងសង្គម និងសេដ្ឋកិច្ចតាមរយៈការផ្តល់ជូននូវសេវាកម្មយ៉ាងទូលំទូលាយសម្រាប់គាំទ្រជីវិតរស់នៅក្នុងគ្រួសារ និងការតាំងទីលំនៅប្រកបដោយស្ថេរភាពរបស់គ្រួសារពហុវប្បធម៌។ |
| មូលដ្ឋានច្បាប់ | ·មាត្រា 21 នៃច្បាប់មូលដ្ឋានស្តីពីសុខភាពគ្រួសារ( ការគាំទ្រដល់គ្រួសារ ),<br>មាត្រា35( ការចាត់តាំងមជ្ឈមណ្ឌលគាំទ្រសុខភាពគ្រួសារ )<br>·មាត្រា 6 នៃច្បាប់គាំពារគ្រួសារពហុវប្បធម៌( ផ្តល់ព័ត៌មានរស់នៅ និង គាំទ្រផ្នែកអប់រំ ),<br>មាត្រា 12 ( ការចាត់តាំងនិងប្រតិបត្តិការមជ្ឈមណ្ឌលគាំពារគ្រួសារពហុវប្បធម៌ ជាដើម ) |
| សាជីវកម្មប្រតិបត្តិការ | ( និមិត្តសញ្ញាមូលនិធិ )រួបរួមជាមួយ មូលនិធិម៉ាអឺម |
| កាលបរិច្ឆេទបើក | ·មជ្ឈមណ្ឌលគាំទ្រសុខភាពគ្រួសារខណ្ឌស៊ូសុង ថ្ងៃទី1 ខែ4 ឆ្នាំ2009<br>·មជ្ឈមណ្ឌលគាំពារគ្រួសារពហុវប្បធម៌ខណ្ឌស៊ូសុង ថ្ងៃទី1 ខែ1 ឆ្នាំ2010<br>·មជ្ឈមណ្ឌលលើកកម្ពស់សុខភាពគ្រួសារនិងគាំពារគ្រួសារពហុវប្បធម៌ខណ្ឌស៊ូសុង ( មជ្ឈមណ្ឌលរួម )ថ្ងៃទី1 ខែ1 ឆ្នាំ2016 |
| គោលដៅប្រើប្រាស់ | ប្រជាជនគ្រប់រូបរស់នៅក្នុងតំបន់ |

**ចក្ខុវិស័យ** សហគមន៍ស៊ូសុង ប្រកបដោយភាពថ្លៃថ្នូរនិងយល់ដឹងរបស់សមាជិកនិងគ្រួសារទាំងអស់។

**បេសកកម្ម** 1. ការអនុវត្តន៍សុខុមាលភាពគ្រួសារដែលគោរពទៅលើភាពចម្រុះ។
2. ការអនុវត្តន៍សុខុមាលភាពគ្រួសារតាមរយៈការចូលរួមដោយប្រធានបទនិង ការទំនាក់ទំនងទៅវិញទៅមក។

**វិធីសាស្រ្ត** 1. ការពង្រីកសេវាកម្មគ្រួសារជាសកលតាមវដ្តជីវិតសម្រាប់គ្រួសារចម្រុះ។
2. ការធ្វើឱ្យសកម្មនៃសេវាកម្មជីវិតរស់នៅក្នុងគ្រួសារតាមតម្រូវការស្របតាមលក្ខណៈរបស់គ្រួសារនីមួយៗ។
3. ការពង្រឹងសេវាកម្មថែទាំគ្រួសារតាមតម្រូវការសម្រាប់ប្រភេទនៃគ្រួសារនីមួយៗ។
4. ការធ្វើឱ្យសកម្មនៃសហគមន៍មូលដ្ឋានមានលក្ខណៈជាមិត្តភាពគ្រួសារសម្រាប់ការចូលរួមនិងប្រាស្រ័យទាក់ទង។
**រចនាសម្ព័ន្ធរបស់អង្គភាព**



## កិច្ចការអភិវឌ្ឍន៍ទំនាក់ទំនងគ្រួសារ

ពង្រឹងតួនាទីមាតាបិតា, កែលម្អទំនាក់ទំនងគ្រួសារ, ទំនាក់ទំនងគ្រួសារ, គាំទ្រសេវាកម្មតាមតម្រូវការដើម្បី
ពង្រឹងសមត្ថភាពរបស់សមាជិកគ្រួសារ, ដោះស្រាយបញ្ហានិងទំនាស់គ្រួសារ តាមប្រភេទគ្រួសារ
វដ្តជីវិត និងប្រភេទបញ្ហានីមួយៗ, គាំទ្រជំរុញនូវការយល់ដឹងអំពីសមភាពយេនឌ័រ និងសិទ្ធមនុស្ស

**អប់រំតួនាទីជាមាតាបិតា និង ប្តីប្រពន្ធ(សាលារៀនបាប៉ាបុម អប់រំបណ្តុះបណ្តាលមាតាបិតា)**

·គាំទ្រដើម្បីបំពេញតួនាទីសំខាន់នៃប្រធានបទអប់រំក្នុងគ្រួសារ តាមរយៈមាតាបិតាធ្វើការយល់ដឹងយ៉ាងត្រឹមត្រូវអំពីការចិញ្ចឹមបិបាច់ និងការអប់រំស្របតាមការលូតលាស់របស់កុមារ។
·តាមវដ្តជីវិតនីមួយៗ(អប់រំមាតាបិតាដល់កន្លែង, អប់រំមាតាបិតា សម្រាប់អ្នកត្រៀមក្លាយជាមាតាបិតា និងអ្នកមានកូនវ័យកុមារ·វ័យជំទង់·វ័យកណ្តាល)
·តាមប្រភេទគ្រួសារ(អប់រំឪពុក, អប់រំមាតាបិតា ដល់គ្រួសារប្រកបការងារទាំងប្តីនិងប្រពន្ធ·គ្រួសាររៀបការម្តង់ទៀត·គ្រួសារមានតែឪពុកឬម្តាយ·គ្រួសារមានកូនពិការភាព)
·តាមអាកប្បកិរិយារបស់កុមារ( ផ្លូវភេទរបស់កុមារ, កែលម្អទំនាក់ទំនងមិត្តភាព, កាត់បន្ថយការប្រើប្រព័ន្ធផ្សព្វផ្សាយហួសហេតុរបស់កុមារ ជាដើម)
·អប់រំកម្រិតខ្ពស់(ប្រឹក្សាគ្រួសារ បាប៉ាបុម, ប្រឹក្សាបណ្តុះបណ្តាលពីការចិញ្ចឹមកូន, ដំណើរកំសាន្តគ្រួសារ, ការប្រកួតប្រជែងសសរសេរ, ក្រុមជួបប្រជុំ)

**ប្រឹក្សាគ្រួសារ**

·ផ្តល់ជូនសេវាកម្មប្រឹក្សាឯកទេសសម្រាប់ការពារ និងដោះស្រាយបញ្ហាជាច្រើនដែលបានកើតឡើងនៅក្នុងគ្រួសារ។
·ប្រឹក្សាគ្រួសារ, ប្រឹក្សាពេលមុន និងក្រោយពេល លែងលះ, ប្រឹក្សាជម្លោះ ពេលមានផ្ទៃពោះ និងសម្រាល
រយៈពេលប្រតិបត្តការ : ថ្ងៃច័ន្ទ~: ថ្ងៃសៅរ៍ 09:00 – 18:00 ※អនុវត្តន៍ការប្រឹក្សាពេលយប់(ថ្ងៃអង្គារ៍, ថ្ងៃព្រហស្បតិ៍)
របៀបប្រតិបត្តការ : មួយសប្តាហ៍ 1ដង ប្រឹក្សាដោយមកមជ្ឈមណ្ឌលផ្ទាល់ ※មួយដង 50នាទី, 10ដង
※អាចនឹងត្រូវចំណាយពេលរងចាំនៅពេលដាក់ពាក្យ, ប្រតិបត្តិការដោយមូលដ្ឋានកក់ទុកជាមុន។

**គាំទ្រលើកកម្ពស់ទំនាក់ទំនងគ្រួសារ**

·អប់រំកែលម្អរវេទយិតភាពសិទ្ធមនុស្ស និងសមភាពយេនឌ័រ ដើម្បីលើកកម្ពស់ទំនាក់ទំនងប្តីប្រពន្ធគ្រួសារពហុវប្បធម៌

**គាំទ្រសម្រាប់ការលូតលាស់របស់កុមារគ្រួសារពហុវប្បធម៌ ‘ទេពកោសល្យ(多)ចម្រុះ’**

·គាំទ្រសកម្មភាពវប្បធម៌អប់រំសម្រាប់កែលម្អរទំនាក់ទំនងមាតាបិតានិងកូន ការអភិវឌ្ឍន៍សង្គមរបស់កុមារ។
·ធ្វើតេស្តសមត្ថភាពសម្រាប់រៀបគម្រោងនាពេលអនាគត, គាំទ្រការធ្វើបទពិសោធន៍ការងារ ជាដើម។
·ផ្តល់ជំនួយប្រឹក្សាករណីមានវិបត្តិ(ភ្ជាប់ទំនាក់ទំនងជាមួយអង្គការពាក់ព័ន្ធក្នុងតំបន់)

**បង្កើតបរិយាកាសពីរភាសាសម្រាប់គ្រួសារពហុវប្បធម៌**

▶គ្រួសារពហុវប្បធម៌ដែលមានកូនចាប់ពីវ័យទារក – ត្រឹម12ឆ្នាំ
·បណ្តុះបណ្តាលមាតាបិតាដើម្បីបង្កើតបរិយាកាសពីរភាសា, កម្មវិធីធ្វើអន្តរកម្មរវៀងមាតាបិតានិងកូន,
ផ្តល់ជូនកម្មវិធីប្រើប្រាស់ពីរភាសា

## កិច្ចការគាំទ្រថែទាំគ្រួសារ

គាំទ្រសេវាកម្មថែទាំដល់គ្រួសារមានសមត្ថភាពខ្សត់ខ្សោយ
ដោយសារតែ អវត្តមានបណ្តោះអាសន្ន ឬ រយៈពេលវែងនៃសមាជិកគ្រួសារ និងស្ថានភាពមានវិបត្តិ
គាំទ្រសេវាកម្មពង្រឹងមុខងារគ្រួសារតាមតម្រូវការតាមប្រភេទលក្ខណៈគ្រួសារ

**គាំទ្រក្តីសង្ឃឹមនិងក្តីសុបិន្តគ្រួសារ**

▶គ្រួសារដែលមានសមត្ថភាពខ្សត់ខ្សោយមានដូចជា គ្រួសារមានសមាជិកតែ1នាក់, ឪពុកម្តាយវ័យជំទង់, គ្រួសារដែលចៅៗរស់នៅជាមួយជីដូនជីតា។ល។
※គ្រួសារដែលប្រឈមមុខនឹងគ្រោះវិបត្តិ / ស្តង់ដារនៃប្រាក់ចំណូលមធ្យមក្រោម100%
·គាំទ្រផ្លូវអារម្មណ៍ និងការអប់រំ, គាំទ្រជំនួយក្នុងការរស់នៅ, គាំទ្រសេវាកម្មផ្លូវចិត្ត និងប្រឹក្សា។
·អប់រំពង្រឹងសមត្ថភាពមាតាបិតា និងភ្ជាប់ធនធានក្នុងតំបន់

**សេវាកម្មអប់រំតាមគេហដ្ឋានសម្រាប់គ្រួសារពហុវប្បធម៌**

▶ជនរៀបបការអន្តោប្រវេសន៍ និង កុមារគ្រួសារពហុវប្បធម៌ដែលពិបាកក្នុងការអញ្ជើញមកដល់មជ្ឈមណ្ឌលផ្ទាល់
·អប់រំភាសាកូរ៉េៈ ជនរៀបបការអន្តោប្រវេសន៍ និង
កុមារដែលកើតធំឡើងនៅបរទេសបានធានាមករស់នៅប្រទេសកូរ៉េ 80ដង(10ខែ)
·អប់រំមាតាបិតាៈ អប់រំមាតាបិតា តាមវដ្តជីវិតនីមួយៗ ចំនួន40ដង(5ខែ)/សរ៉ុបចំនួន 120ដង
1) មានផ្ទៃពោះ និងសម្រាល 2) វ័យទារក 3) វ័យកុមារ
·សេវាកម្មជីវិតរស់នៅរបស់កុមារៈ កុមារដែលកើតធំឡើងនៅបរទេសបានធានាមករស់នៅប្រទេសកូរ៉េ
និង កុមារគ្រួសារពហុវប្បធម៌ 80ដង(10ខែ)

**គាំទ្រកុមារដែលកើតធំឡើងនៅបរទេសបានធានាមករស់នៅប្រទេសកូរ៉េ**

▶កុមារដែលកើតធំឡើងនៅបរទេសបានធានាមករស់នៅប្រទេសកូរ៉េ
( កុមារគ្រួសារពហុវប្បធម៌ដែលចូលមកប្រទេសកូរ៉េបន្ទាប់ពីបានធំឡើងនៅបរទេស)
·អប់រំភាសាកូរ៉េ និង គាំទ្របង្រៀនមុខវិជ្ជាមូលដ្ឋាន, សេវាកម្មណែនាំផ្តល់ដំបូលន្មាន ជាដើម។

**គ្រប់គ្រង់ករណីគ្រួសារពហុវប្បធម៌**

▶គ្រួសារពហុវប្បធម៌រស់នៅខណ្ឌស៊ូសុងដែលមិនអាចប្រើប្រាស់សេវាសង្គមផ្សេងៗបានដោយសារតែខ្វះខាតព័ត៌មាននិងខ្វះខាតប្រាក់ចំណូល។
·ប្រឹក្សាជាបន្តបន្ទាប់ និង ធ្វើការត្រួតពិនិត្យ
·ដោះស្រាយបញ្ហាប្រចាំថ្ងៃដូចជា គ្រួសារ និងការងារ
·ជំនួយនៅគ្រាអាសន្នមានវិបត្តិ(ការព្យាបាលវេជ្ជសាស្ត្រ, រំលោភបំពាន និង ហឹង្សា, លែងលះ, បាក់ទឹកចិត្ត, ការប៉ុងធ្វើអត្តឃាត ជាដើម)
·សេវាកម្មតាមតម្រូវការតាមរយៈការភ្ជាប់ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌល និងធនធានសហគមន៍ក្នុងតំបន់។

## កិច្ចការគាំទ្រជីវិតរស់នៅក្នុងគ្រួសារ

គាំទ្រសេវាកម្មជីវិតរស់នៅតាមតម្រូវការ ដូចជា ប្រឹក្សាពីភាពពិបាកតាមលក្ខណៈគ្រួសារនីមួយៗ,
ផ្តល់ជូនព័ត៌មានរស់នៅ, គាំទ្រការតាំងទីលំនៅដំបូង។ល។

**គាំទ្រការរស់នៅដល់គ្រួសារពហុវប្បធម៌**
·ប្រឹក្សានិងផ្តល់ជូលព័ត៌មានដល់គ្រួសារពហុវប្បធម៌។
·ការភ្ជាប់ទំនាក់ទំនងជាមួយអ្នកឧបត្ថម្ភ និងការអប់រំផ្សេងៗដោយប្រើបណ្តាញសហគមន៍មូលដ្ឋាន។
·កម្មវិធីធ្វើបទពិសោធន៍ជាមួយវប្បធម៌កូរ៉េ និង បុណ្យប្រពៃណីកូរ៉េ ជាដើម។

**កិច្ចការគាំទ្រតាំងទីលំនៅមូលដ្ឋានដល់គ្រួសារពហុវប្បធម៌**
·អនុវត្តន៍ការអប់រំយល់ដឹងពីវប្បធម៌កូរ៉េ និងធ្វើបទពិសោធន៍ ដល់គ្រួសារពហុវប្បធម៌ចូលមកក្នុងប្រទេសកូរ៉េដំបូង
(ក្រោម2ឆ្នាំ)

**គាំទ្រការងារជនរៀបការអន្តោប្រវេសន៍**
·ពង្រឹងសមត្ថភាពដើម្បីធ្វើការ និងបង្កើតអាជីវកម្មដល់ជនរៀបការអន្តោប្រវេសន៍តាមរយៈកម្មវិធីការងារដូចជាថ្នាក់រៀនត្រៀមប្រលងយកវិញ្ញាបនបត្រ(ថ្នាក់រៀនត្រៀមប្រលងច្បាប់បើកបរ,ថ្នាក់វិញ្ញាបនបត្រកុំព្យូទ័ ITQ )
·អនុវត្តន៍កិច្ចការបានសម្រេច 多ការតាំងទីលំនៅក្នុងប្រទេសកូរ៉េរបស់គ្រួសារពហុវប្បធម៌(គ្រូបង្រៀនវប្បធម៌សុវត្ថិភាព, គ្រូបង្រៀនធ្វើម្ហូបកុមារ, អប់រំបណ្តុះបណ្តាលចំណេះដឹងការងារ)

**គាំទ្រការស្វែងរកតាមកន្លែងបាំងបិត / គាំទ្រអភិវឌ្ឍន៍គោលនយោបាយពិសេស**
·បញ្ជូនជំនួយការទំនាក់ទំនងសម្រាប់គាំទ្រដល់ជីវិតរស់នៅប្រចាំថ្ងៃ, គាំទ្រសេវាកម្មបកប្រែ POOL
·ផ្តល់ជូនព័ត៌មានជាពហុភាសាទាក់ទងនឹងការចិញ្ចឹមកូន, គាំទ្រការប្រឹក្សាផ្លូវចិត្ត(ពិនិត្យធ្វើតេស្ត)

**បង្កើតបណ្តាញសុវត្ថិភាពនៃការចូលរួមក្នុងសង្គមសម្រាប់កុមារនៃគ្រួសារពហុវប្បធម៌**
·다채움: គាំទ្រការប្រឹក្សាផ្លូវអារម្មណ៍ និងអាជីព ការងារ 1:1 ដល់កុមារវ័យសិក្សារបស់គ្រួសារពហុវប្បធម៌មានអាយុចាប់ពី7ឆ្នាំ~18ឆ្នាំ។
·다배움: គាំទ្រការបង្រៀនសម្រាប់ត្រៀមចូលសាលារៀនដល់កុមារគ្រួសារពហុវប្បធម៌ដែលមិនទាន់ចូលសិក្សានៅសាលារៀន ឬកំពុងសិក្សាថ្នាក់បឋមសិក្សាចាប់ពីថ្នាក់ទី1ដល់ថ្នាក់ទី3(អក្សរកូរ៉េ, ភាសាកូរ៉េ, គណិតវិទ្យា ជាដើម)

**គាំទ្រដល់គ្រួសារមានសមាជិក1នាក់**
· ការអប់រំចម្រុះស្របតាមលក្ខណៈនៃគ្រួសារដែលមានសមាជិកតែម្នាក់ដើម្បីលើកកម្ពស់សមត្ថភាពថែទាំខ្លួនឯង និងគាំទ្រការសម្របខ្លួន, យុទ្ធនាការបរិស្ថាន, គាំទ្រផ្លូវចិត្តផ្លូវអារម្មណ៍ និងគាំទ្រកិច្ចជួបប្រជុំ។

**គាំទ្រពង្រឹងសមត្ថភាពជនរៀបការអន្តោប្រវេសន៍**
▶ជនរៀបការអន្តោប្រវេសន៍ និង កុមារដែលកើតធំឡើងនៅបរទេសបានធានាមករស់នៅប្រទេសកូរ៉េ
※និស្សិតបរទេស និង ជនបរទេសក៏អាចចូលរួមជាមួយថ្នាក់សិក្សាបាន
·អនុវត្តន៍ការអប់រំភាសាកូរ៉េជាក្រុមតាមកម្រិតនីមួយៗ(កម្រិតបឋម, កម្រិតមធ្យម, កម្រិតខ្ពស់)
·ប្រតិបត្តិការថ្នាក់ត្រៀមប្រលងចូលសញ្ជាតិ និងត្រៀមប្រលងសាកល្បងសមត្ថភាពភាសាកូរ៉េ(TOPIK)
·ការប្រលងសរសេរតែងសេចក្តីភាសាកូរ៉េ, ការវាយតម្លៃសមត្ថភាពភាសាកូរ៉េដោយខ្លួនឯងក្នុងឆមាសទីមួយនិងឆមាសទីពីរ

**គាំទ្រការបកប្រែដល់ជនរៀបការអន្តោប្រវេសន៍**
▶បុគ្គល ឬអង្គការដែលឧបបត្ថម្ភគាំទ្រដោយផ្ទាល់ ឬប្រយោលដល់ជនរៀបការអន្តោប្រវេសន៍ និងគ្រួសារពហុវប្បធម៌
·ការបកប្រែផ្ទាល់មាត់ បកប្រែឯកសារ ផ្តល់ជូនព័ត៌មាន។ល។ ដើម្បីគាំទ្រដល់កាប្រាស្រ័យទាក់ទងចាំបាច់សម្រាប់ជីវិតរស់នៅក្នុងគ្រួសារ និងសង្គម របស់ជនរៀបការអន្តោប្រវេសន៍ដែលមានសមត្ថភាពខ្សោយក្នុងការនិយាយភាសាកូរ៉េ។
※សម្រាប់គោលបំណងធ្វើពាណិជ្ជកម្ម, មិនអាចចេញនូវលិខិតបញ្ជាក់ស្របតាមផ្លូវច្បាប់បានទេ។
※សម្រាប់ភាសាផ្សេងទៀតក្រៅពីភាសាចិន អាចភ្ជាប់ទំនាក់ទំនងទៅកាន់មជ្ឈមណ្ឌលផ្សេងទៀតបាន។
·ណែនាំប្រើប្រាស់ : មកដល់មជ្ឈមណ្ឌលផ្ទាល់ និង តាមទូរស័ព្ទ, អ៊ីម៉ែល, ហ្វាក់ ជាដើម។

**គាំទ្រអភិវឌ្ឍន៍ភាសាដល់កុមារគ្រួសារពហុវប្បធម៌**
▶កុមារគ្រួសារពហុវប្បធម៌(មានអាយុក្រោម 12ឆ្នាំ)
※គោលដៅជ្រើសជ្រើសជាដំបូង : ជនដែលទទួលបានការទ្រទ្រង់ជីវភាពរស់នៅមូលដ្ឋានពីរដ្ឋ,
គ្រួសារដែលមានតែឪពុកឬម្តាយ, គ្រួសារដែលចៅៗរស់នៅជាមយយជីដូនជីតា។ល។
(អាចមានការគាំទ្រដល់ គ្រួសារដែលចាកចេញពីប្រទេសកូរ៉េខាងជើង និងគ្រួសារបរទេសតាមស្ថានភាពនៃតំបន់នីមួយៗ)
·ធ្វើការវាយតម្លៃនៃការអភិវឌ្ឍន៍ភាសារបស់កុមារ, អប់រំអភិវឌ្ឍន៍ភាសា, ប្រឹក្សាមាតាបិតាទាក់ទងនឹងការអភិវឌ្ឍន៍ភាសា
·ណែនាំការប្រើប្រាស់ : ដាក់ពាក្យជាមួយសេវាកម្ម > ប្រឹក្សាដំបូង និង ធ្វើការវាយតម្លៃ > អប់រំភាសា
> វឌ្ឍនភាព និងការវាយតម្លៃបញ្ចប់ > ការគ្រប់គ្រងពេលក្រោយ

**គណនីយទេវតាក្តីសង្ឃឹមស៊ូសុង ‘ពីធីអបបអរសាទរកំណើតនៃសមាជិកគ្រួសារ’**
▶កុមារដែលកើតនៅក្នុងគ្រួសារពហុវប្បធម៌ និងគ្រួសារមានប្រាក់ចំណូលទាប(ក្នុង 100% នៃប្រាក់ចំណូលមធ្យម)
រស់នៅខណ្ឌស៊ូសុង
·ការជួលតុ រៀបចំតុបតែងបុណ្យគម្រប់មួយរយថ្ងៃ និងគម្រប់មួយខួប, ថតរូបអនុស្សាវរីយ៍

កិច្ចការបង្កើតសហគមន៍មូលដ្ឋានជាមួយគ្រួសារ

វប្បធម៌គ្រួសារសមភាពយេនឌ័រ, វប្បធម៌សហគមន៍របស់សង្គមក្នុងតំបន់,
បង្កើតបរិយាកាសសង្គមមិត្តភាពគ្រួសារ, អភិវឌ្ឍន៍ការយល់ដឹងពីពហុវប្បធម៌
គាំទ្រសេវាកម្មភ្ជាប់ទំនាក់ទំនងគ្រួសារនិងសហគមន៍

**អភិវឌ្ឍន៍ការយល់ដឹង និង យល់ដឹងពីសហគមន៍**
·យុទ្ធនាការស្វែងយល់ពីលក្ខណៈនៃគ្រួសារចម្រុះមានដូចជា គ្រួសារពហុវប្បធម៌ គ្រួសារមានតែឪពុក ឬម្តាយ គ្រួសារដែលចៅៗរស់នៅជាមួយជីដូនជីតា គ្រួសាររត់គេចចេញពីប្រទេសកូរ៉េខាងជើង និងលុបបំបាត់ការរើសអើង។

**កម្មវិធីវប្បធម៌មិត្តភាពគ្រួសារ**
·ដំណើរការពិធីបុណ្យក្នុងស្រុកភូមិរបស់យើងដូចជាពិធីបុណ្យគ្រួសារ( ការប្រកួតកីឡា,ទីផ្សារលក់ទំនិញបរិច្ចាក )ជាដើម

**ក្រុមស្ម័គ្រចិត្តចែករំលែកគ្រួសារពហុវប្បធម៌**
·ការសម្តែងចែករំលែកទេពកោសល្យក្នុងសហគមន៍តាមរយៈការហ្វឹកហាត់តាមកាលកំណត់របស់
ក្រុមច្រៀង해피코러스

**ទិវានៃក្តីស្រឡាញ់គ្រួសារ**
·'ទិវានៃក្តីស្រឡាញ់គ្រួសារ' ដើម្បីផ្សព្វផ្សាយសហគមន៍ ដោយធ្វើការអនុវត្តន៍ជារៀងរាល់សប្តាហ៍នាថ្ងៃពុធ។

**កញ្ចប់គាំទ្រតាមដំណាក់កាលនៃការតាំងទីលំនៅនីមួយៗដល់ជនរៀបការអន្តោប្រវេសន៍**
·ជនរៀបការអន្តោប្រវេសន៍រៀបគម្រោងចំពោះនិតិវិធីនៃការតាំងទីលំនៅរបស់ពួកគេ និងស្វែងរកសេវាកម្មពាក់ព័ន្ធ ដោយខ្លួនឯងផ្ទាល់, គាំទ្របង្កើតគម្រោងការអនុវត្តន៍។ល។
-កម្មវិធីរៀបចំគម្រោងនាពេលអនាគត។
-ស្វែងរកផ្លូវឆ្ពោះទៅកាន់សង្គមយ៉ាងទូលំទូលាយ។
-ស្វែងរកប្រព័ន្ធព័ត៌មានរបស់សេវាកម្មគាំទ្រការតាំងទីលំនៅ។

**កម្មវិធីសម្របខ្លួនដំបូងសម្រាបប់ជនរៀបការអន្តោប្រវេសន៍**
·អប់រំអំពីច្បាប់ និងបទបញ្ញាទាក់ទងជាមួយការស្នាក់នៅ ចូលសញ្ជាតិ ហើយនិងច្បាប់មូលដ្ឋាន និងប្រព័ន្ធ រួមជាមួយនឹង ការព្យាបាលវេជ្ជសាស្ត្រ លំនៅដ្ឋាន ចរាចរណ៍ធ្វើដំណើរ គមនាគមន៍ និងព័ត៌មានរស់នៅដែលត្រូវការចាំបាច់ដើម្បី សម្របខ្លួនក្នុងសង្គមកូរ៉េរបស់ជនរៀបការអន្តោបប្រវេសន៍ និងសមាជិកគ្រួសារពហុវប្បធម៌។
※ ផ្តល់ជូនសេវាកម្មបកប្រែដោយផ្ទួផ្ទងជាមួយអ្នកផ្តល់ដំបូលន្មានមានសញ្ជាតិដូចគ្នាជាមួយប្រទេសរបស់អ្នកចូលរួម។

**កិច្ចការថាអ៊ីអឹម ការអប់រំយល់អំពីពហុវប្បធម៌ដល់កន្លែងដែលមានគ្រូជាជនរៀបការអន្តោប្រវេសន៍**
·អនុវត្តន៍ការអប់រំយល់ដឹងអំពីពហុវប្បធម៌ដល់កន្លែងតាមរយៈការភ្ជាប់ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធក្នុងតំបន់ដូចជា ផ្ទះកុមារ និងសាលាបឋមសិក្សាជាដើម។
·ការអប់រំ និងធ្វើបទពិសោធន៍នៃវប្បធម៌របស់ប្រទេសផ្សេងៗ
※ប្រទេសចិន, ប្រទេសវៀតណាម, ប្រទេសកម្ពុជា, ប្រទេសរុស្ស៊ី, ប្រទេសអ៊ូសបេគីស្ថាន។ល។
·យុទ្ធនាការផ្សព្វផ្សាយសហគមន៍។

**កិច្ចជួប្រជុំគ្រួសារពហុវប្បធម៌**
·ដំណើការកិច្ចជួបប្រជុំដើម្បីជួយខ្លួនឯងសម្រាប់គោលបំណងផ្សេងៗដែលដឹកនាំដោយជនរៀបការអន្តោប្រវេសន៍
·អនុវត្តន៍ការជួបប្រជុំសង្ខេបដល់អ្នកដឹកនាំចូលរួម និងការប្រជុំផ្លាស់ប្តូរទាំងស្រុង។

**កិច្ចការគាំទ្រសហគមន៍ថែទាំ**
·គាំទ្រដល់ការពង្រឹងសមត្ថភាពរបស់សហគមន៍ថែទាំ ដើម្បីធ្វើឱ្យសហគមន៍ថែទាំយកចិត្តទុកដាក់ដែលអាចបំពេញបន្ថែម ដែនកំណត់នៃការថែទាំ និងបង្កើតបណ្តាញថែទាំប្រកបដោយសុវត្ថិភាពជាមួយប្រជាជនក្នុងមូលដ្ឋាន។
▶អ្នកមានមុខវិជ្ជាថែទាំមនុស្សពេញវ័យ លើសពី5នាក់, សមាសភាពកុមារមានអាយុចាប់ពី 0ឆ្នាំ~ 12ឆ្នាំ លើសពី 8នាក់
-សហគមន៍ថែទាំគឺជាការអនុវត្តន៍ការថែទាំប្រចាំថ្ងៃ ថែទាំបណ្តោះអាសន្នសម្រាប់កុមារ។

**កិច្ចការនៃក្តីសុបិន្ត**(Dream) **គ្រួសារ**( 家)
▶មាតាបិតាដែលខ្វះខាតលំនៅដ្ឋានកំពុងចិញ្ចឹមកូនមានអាយុក្រោម12ឆ្នាំ
·អប់រំបង្កើតបរិយាកាសថែទាំជាប្រភេទតាមតម្រូវការសម្រាប់លើកម្ពស់សុខភាពគ្រួសាររបស់កុមារក្រីក្រខ្វះលំនៅដ្ឋាន។
-អប់រំបណ្តុះបណ្តាលអំពីការចិញ្ចឹមកូន, អបប់រំកែលម្អអាហាររូបត្ថម្ភ, អប់រំបណ្តុះបណ្តាលអំពីការរៀបចំទុកដាក់ 1:1តាមត្រូវការ។

## កិច្ចការមជ្ឈមណ្ឌលចែករំលែកព័ត៌មានចិញ្ចឹមកូនជាសាធារណៈ
## ទីកន្លែងសម្រាប់ផ្លាស់ប្តូរនិងទំនាក់ទំនងរបស់គ្រួសារពហុវប្បធម៌(다가ON)

·ដំណើរការកន្លែងដល់មាតាបិតានិងកូន សម្រាប់គ្រួសារផ្សេងៗទាំងឡាយជួបជុំ ដើម្បីចែករំលែកព័ត៌មានចិញ្ចឹមកូន ហើយកុមារអាចប្រើប្រាស់សេវាសម្ភារៈក្មេងលេង និងសៀវភៅដោយសេរី និងមានភាពងាយស្រួល។
·លើកកម្ពស់ការប្រាស្រ័យទាក់ទងជាក់ស្តែង និងការបង្រួបបង្រួមរវាងគ្រួសារពហុវប្បធម៌ និងសហគមន៍មូលដ្ឋាន ដើម្បីពង្រីកសមាហរណកម្មសហគមន៍ និងការចូលរួមក្នុងសង្គម

| ការបែងចែក | | ពេលវេលាប្រើប្រាស់ | ទីកន្លែង | ខ្លឹមសារ |
|---|---|---|---|---|
| មជ្ឈមណ្ឌលចែករំលែកព័ត៌មានចិញ្ចឹមកូនជាសាធារណៈ | 두산<br>ឌូសាន | ច័ន្ទ~សុក្រ<br>09:00~18:00 | មជ្ឈមណ្ឌលគ្រួសារដេគូខណ្ឌស៊ូសុង ជាន់ទី2 | ·បើកដំណើរការទីកន្លែងចែករំលែកព័ត៌មានចិញ្ចឹមកូនជាសាធារណៈ |
| | 수성<br>ស៊ូសុង | ច័ន្ទ~សៅរ៍<br>09:00~18:00 | មជ្ឈមណ្ឌលសុខុមាលភាពស៊ូសុងអគារ가 2·3 ជាន់ទី2 | ·បើកដំណើរការទីកន្លែងចែករំលែកព័ត៌មានចិញ្ចឹមកូនជាសាធារណៈ<br>·កម្មវិធីចូលរួមរវៀងមាតាបិតានិងកូន (មួយសប្តាហ៍ 2ដង)<br>·បើកដំណើរការបណ្ណាល័យសម្ភារៈក្មេងលេង |
| | 용학<br>យ៉ុងហាក់ | អង្គារ៍~សុក្រ<br>12:00~16:00 | បណ្ណាល័យយ៉ុងហាក់ ជាន់ទី2 | ·បើកដំណើរការបណ្ណាល័យសម្ភារៈក្មេងលេង |
| | 지산<br>ជីសាន់ | ច័ន្ទ~សុក្រ<br>10:00~19:00<br>សៅរ៍<br>09:00~18:00 | ស្ថាប័នគាំទ្រគ្រួសារដែលមានម្តាយនិងកូនម៉ុកល្យ៉ុនជីសាន់ | ·បើកដំណើរការទីកន្លែងចែករំលែកព័ត៌មានចិញ្ចឹមកូនជាសាធារណៈ<br>·បើកដំណើរការថ្នាក់មើលថែទាំសិស្សបឋម<br>·កម្មវិធីចូលរួមដោយសិស្សថ្នាក់បឋម (មួយសប្តាហ៍ 5ដង) |
| | 범어<br>ប៊ុមអរ | ច័ន្ទ~សៅរ៍<br>09:00~18:00 | មជ្ឈមណ្ឌលសុខុមាលភាពស៊ូសុងអគារលេខ3ប៊ុមអរ ជាន់ទី3 | ·បើកដំណើរការទីកន្លែងចែករំលែកព័ត៌មានចិញ្ចឹមកូនជាសាធារណៈ<br>·កម្មវិធីចូលរួមដោយកុមារតូចនិងសិស្សថ្នាក់បឋម(មួយសប្តាហ៍ 2ដង)<br>·បើកដំណើរការបណ្ណាល័យសម្ភារៈក្មេងលេង |
| ទីកន្លែងសម្រាប់ផ្លាស់ប្តូរនិងទំនាក់ទំនងរបស់គ្រួសារពហុវប្បធម៌(다가ON) | | ច័ន្ទ~សុក្រ<br>09:00~18:00 | ពិភពលោកដែលងាយស្រួល eប៊ុមអរ អគារលេខ108 ជាន់ទី1 | ·កម្មវិធីសមាហរណកម្មសហគមន៍지<br>·កម្មវិធីមើលថែទាំកុមារ<br>·កម្មវិធីទាក់ទងជាមួយការលូតលាស់របស់កុមារ<br>·ដំណើរការកម្មវិធីជួបប្រជុំសម្រាប់ជនរៀបការអន្តោប្រវេសន៍ |
| ណែនាំការប្រើប្រាស់បណ្ណាល័យសម្ភារៈក្មេងលេង | | ណែនាំការប្រើប្រាស់ : ជួលសម្ភារៈច្រើនបំផុត 2ប្រភេទ ក្នុង 1សប្តាហ៍សម្រាប់មួយគ្រួសារ<br>※តម្លៃជួលសម្ភារៈក្នុងមួយមុខចាប់ពី 500វ៉ុន~1,000វ៉ុន, ការប្រើប្រាស់ដោយឥតគិតថ្លៃចំពោះទីកន្លែងរបស់មជ្ឈមណ្ឌលចែករំលែកព័ត៌មានចិញ្ចឹមកូនជាសាធារណៈ | | |

## កិច្ចការនៃការជួយគ្នាទៅវិញទៅមកក្នុងការមើលថែទាំកូន

▶គ្រួសារដែលមានកូនវ័យកុមារភាព និង វ័យសិក្សាថ្នាក់បឋម
·ការធ្វើសកម្មភាពជាក្រុម : អនុវត្តន៍ធ្វើសកម្មភាពជាក្រុមនៃប្រភេទផ្សេងៗគ្នា ក្រោយពេលបង្កើតក្រុមជួយគ្នាទៅវិញទៅមករួច។
·ការជួបជុំទាំងអស់ : អនុវត្តន៍ការជួបជុំទាំងអស់គ្នាសម្រាប់ក្រុមជួយគ្នាទៅវិញទៅមកគ្រប់រូប (ជួបប្រជុំសង្ខេប, ទីផ្សារចែករំលែក, ជប់លៀងញ៉ាំអាហារពេលល្ងាច ជាដើម)
·ការអប់រំដល់ជនជាគោលដៅទាំងអស់ : : អនុវត្តន៍កម្មវិធីអប់រំលើកកម្ពស់ទំនាក់ទំនងគ្រួសារ ដែលត្រូវការក្នុងការថែទាំ ឬចិញ្ចឹមកុមារ ដែលបានផ្តល់ជូនដល់ក្រុមធ្វើសកម្មភាពជួយគ្នាទៅវិញទៅមក។
·អប់រំបណ្តុះបណ្តាលដល់អ្នកធ្វើសកម្មភាពជួយគ្នាទៅវិញទៅមក : អនុវត្តន៍ការអប់រំពង្រឹងសមត្ថភាព និងការអប់រំចែករំលែកទេពកោសល្យដល់អ្នកដឹកនាំចែករំលែក និងអ្នកបម្រុងធ្វើជាអ្នកដឹកនាំចែករំលែក។
※នៅពេលចូលរួមធ្វើសកម្មភាពជួយគ្នាទៅវិញទៅមកក្នុងការមើលថែទាំកូន អ្នកនឹងត្រូវទទួលបានការលើកលែងថ្លៃចូលរួមជាមួយកម្មវិធីអចិន្ត្រៃយ៍ និងអាចជួលសម្ភារៈក្មេងលេងបានចំនួន4 ក្នុងមួយខែដោយឥតគិតថ្លៃ។

ណែនាំការប្រើប្រាស់: ចែករំលែកតម្រូវការនៃការជួយគ្នាទៅវិញទៅមកក្នុងការមើលថែទាំកូន > ទូរស័ព្ទ និង មកកាន់មជ្ឈមណ្ឌលផ្ទាល់ > បង្កើតក្រុមជួយគ្នាទៅវិញទៅមកក្នុងការមើលថែទាំកូន > អប់រំជួយគ្នាទៅវិញទៅមកក្នុងការមើលថែទាំកូន > អនុវត្តន៍សកម្មភាពជាក្រុម > គាំទ្រកម្មវិធីយ៉ាងសំបូរបែបនៅក្នុងមជ្ឈមណ្ឌល

# កិច្ចការគាំទ្រមើលថែទាំកុមារ

ផ្តល់ជូនសេវាកម្មមើលថែទាំកុមារដោយបញ្ជូននាក់ថែទាំទៅថែទាំកុមាររបស់គ្រួសារដែលមានគម្លាតនៃការចិញ្ចឹមកូនដោយសារហេតុផលមានដូចជា ឪពុកម្តាយធ្វើការរកប្រាក់ចំណូលទាំងពីរនាក់ និងបន្ទុកនៃការចិញ្ចឹមកូន កាត់បន្ថយបន្ទុកមាតាបិតា និងបំពេញបន្ថែមចំណុចដែលបិតបាំងនៃកន្លែងថែទាំកុមារ

▶កុមារមានអាយុចាប់ពី 3ខែ~ 12ឆ្នាំ នៃគ្រួសារដែលកើតមាននូវគម្លាតក្នុងការថែទាំកូនដោយសារហេតុផលមានដូចជា ឪពុកម្តាយធ្វើការរកប្រាក់ចំណូលទាំងពីរនាក់ និងបន្ទុកនៃការចិញ្ចឹមកូន។ល។

ស្តង់ដារនៃការហាមឃាត់ការឧបត្ថម្ភស្មួនពីរដ្ឋាភិបាលក្នុងការចិញ្ចឹមកូន

- សម្រាប់កុមារដែលទទួលបានការឧបត្ថម្ភថ្លៃចំណាយមើលថែទាំ និងការចំណាយថ្លៃសាលារបស់កុមារតូច មិនអាចទទួលបានការឧបត្ថម្ភពីរដ្ឋាភិបាលបានទេអំឡុងពេលប្រើប្រាស់សេវាតាមកន្លែងថែទាំកុមារ និងសាលាមត្តេយ្យ (ផ្ទះកុមារ : ម៉ោង9~ម៉ោង16, សាលាមត្តេយ្យ : ម៉ោង9~ម៉ោង13)
- នៅពេលទទួលការឧបត្ថម្ភពីរដ្ឋាភិបាលនៃប្រព័ន្ធគិតជាម៉ោង, មិនអាចទទួលបានការឧបត្ថម្ភប្រាក់ជំនួយប្រចាំខែរបស់មាតាបិតាបានទេ។

·ប្រាក់ចំណូលគ្រួសារ

- ព្រំដែននៃការឧបត្ថម្ភពីរដ្ឋាភិបាលនឹងមានការផ្លាស់ប្តូរតាមប្រភេទសេវាកម្ម(ប្រភេទ가, 나, 다, 라)យោងតាមប្រាក់ចំណូលគ្រួសារ(បញ្ជាក់ដោយមជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាល)

ខ្លឹមសារសេវាកម្ម

(ស្តង់ដារឆ្នាំ2023)

| ការបែងចែក | ប្រព័ន្ធគិតជាម៉ោង | ប្រព័ន្ធពេញមួយថ្ងៃសម្រាប់ទារក |
|---|---|---|
| អាយុនៃការប្រើប្រាស់ | កុមារមានអាយុចាប់ពី 3ខែ~ 12ឆ្នាំ | ទារកមានអាយុចាប់ពី 3ខែ~36ខែ |
| ថ្លៃប្រើប្រាស់ | ធូថ្លៃបំផុត1,662~ថ្លៃបំផុត11,080វ៉ុន / ក្នុង1ម៉ោង(នឹងមានការគិតថ្លៃបន្ថែមនៅពេលយប់ និងថ្ងៃឈប់សម្រាក) | |
| ខ្លឹមសារ | សេវាកម្មថែទាំកុមារបណ្តោះអាសន្ន, សកម្មភាពលេង ផ្តល់អាហារនិងអាហារសម្រន់ងាយៗ។ ការពារសុវត្ថិភាព និងសុខសន្តិភាពផ្ទាល់ខ្លួន ដោយការជូនទៅ និងទៅទទួលយកពីកន្លែងថែទាំកុមារ និងសាលារៀន (សម្រាប់ទារក, ស្របគ្នានឹងកិច្ចការប្រព័ន្ធពេញមួយថ្ងៃសម្រាប់ទារក) | សកម្មភាពទាំងស្រុងទាក់ទងនឹងការមើលថែទាំទារកមានដូចជា ផ្តល់អាហារដល់ទារក, សម្អាតកំប៉ុងទឹកដោះគោ, ផ្លាស់ប្តូរកន្ទប, ងូតទឹក។ល។ |

※មិនរាប់បញ្ចូលជាមួយការងារផ្ទះ និងការធ្វើម្ហូបអាហារឡើយ។

## ណែនាំការប្រើប្រាស់

| ①ចុះទៅកាន់មជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាល | ②ចុះឈ្មោះចូលជាសមាជិក | ③ដាក់ពាក្យនិងភ្ជាប់សេវាកម្ម |
|---|---|---|
| ចុះទៅកាន់មជ្ឈមណ្ឌលសុខុមាលភាពរដ្ឋបាលនៅតាម ភូមិ/ឃុំ/សង្កាត់ដែលមានយុត្តាធិការលើអាសយដ្ឋាននៃការចុះឈ្មោះស្នាក់នៅរបស់កុមារដើម្បីដាក់ពាក្យសុំជំនួយរដ្ឋាភិបាល | ចុះឈ្មោះចូលជាសមាជិកលើគេហទំព័រ (idolbom.go.kr) សេវាកម្មមើលថែទាំកុមារ | ដាក់ពាក្យស្នើសុំភ្ជាប់សេវាកម្មទៅកាន់មជ្ឈមណ្ឌល (T.053-795-4200) |

| | |
|---|---|
| ⑤ប្រើប្រាស់សេវាកម្ម | ④ទូទាត់ថ្លៃប្រើប្រាស់ |
| | ទូទាត់ថ្លៃប្រើប្រាស់ក្រោយពេលធ្វើកាតសុភមង្គលប្រជាជាតិរួច |

## ណែនាំការឧបត្ថម្ភ

តម្លៃនៃការរួបរួមគ្នាចាប់ផ្តើមឡើងដោយជំហានដំបូងនៃទឹកចិត្ត។

| ឧបត្ថម្ភទៀងទាត់ | ឧបត្ថម្ភបណ្តោះអាសន្ន |
|---|---|
| ការផ្ទេរចេញដោយស្វ័យប្រវត្តិ តាមចំនួនទឹកប្រាក់ដែលខ្ញុំចង់បាន។ | ការឧបត្ថម្ភដោយសេរីនៅពេលអ្នកចង់ឧបត្ថម្ភដោយគ្មានបន្ទុកអ្វីឡើយ។ |

ការឧបត្ថម្ភដែលបានកំណត់ 504-10-427360-1(ធនាគារដេគូ)
ការឧបត្ថម្ភមិនត្រូវបានកំណត់ 505-10-174847-5(ធនាគារដេគូ)

ឧបត្ថម្ភទឹកប្រាក់
-ឧបត្ថម្ភជាសម្ព័ន្ធភាព : អាហារូបករណ៍, ឧបត្ថម្ភការបង្រៀន។ល។
-ឧបត្ថម្ភទៅលើកម្មវិធី(ព្រឹត្តការណ៍) : បុណ្យ, ទិវាកុមារ។ល។

ឧបត្ថម្ភសម្ភារៈប្រើប្រាស់
-សម្ភារៈចាំបាច់ក្នុងការរស់នៅប្រចាំថ្ងៃ, អាហារសម្រន់, កាដូ។ល។

## របៀបប្រើប្រាស់


លេខទូរស័ព្ទ 053)795-4300, 764-4317
053)795-4200(아이돌봄사업팀)
ហ្វាក់ 05)795-4312
អ៊ីម៉ែល happy4300@familynet.or.kr
គេហទំព័រ http://happy4300.familynet.or.kr(កិច្ចការគាំទ្រសុខភាពគ្រួសារ)
http://suseonggu.liveinkorea.kr(កិច្ចការគាំទ្រគ្រួសារពហុវប្បធម៌)


카카오 플러스채널
ប៉ុស្ត៏កាការផ្លូស

인스타그램
អ៊ីនស្តាក្រាម
SSHAPPY4300

페이스북
ហ្វេសប៊ុក

### ផ្លូវដែលត្រូវអញ្ជើញមក




អាសយដ្ឋាន 우)42169 대구광역시 수성구 들안로 16길 78
A ផ្លូវបំបែក들안길3 : 403, 410
B ផ្លូវបំបែក들안길4 : 403, 410-1
C នៅខាងមុខសាលាបឋមសិក្សា들안길 : 349, 수성4, 순환3-1
D ឆ្លងកាត់សាលាបឋមសិក្សា들안길 : 349, 수성4, 순환3-1
E រថភ្លើង ខ្សែទី3 ស្ថានីយ៍ហ្វាងគឹម